ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងនៃបណ្តឹងលេខ: ៦១៥

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

សាលក្រមលេខ: **១៦ "ខ"**

ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅ សាលសវនាការលេខ:២

កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទីដប់ពីរ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោងប្រាំបី សែសិបនាទីព្រឹក។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោងដប់ប្រាំនិងម្ភៃនាទី។

## ចៅក្រម

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

## ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

**<u>ដើមចោទ:</u>** ឈ្មោះ [redacted] **ចាន់ថា** ភេទស្រី កើតឆ្នាំ១៩៨៧ ជាតិខ្មែរ មានអាសយដ្ឋាន [redacted] ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**<u>ចុងចម្លើយ:</u>** ឈ្មោះ [redacted] **នៃឡេង** ភេទប្រុស កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៥ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]។

## អង្គហេតុនិងចំណុចវិវាទ

**ក-ការទាមទាររបស់ដើមចោទ:**

**<u>កម្មវត្ថុបណ្តឹង:</u>** សុំឲ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម៖

១-សុំឲ្យដើមចោទឈ្មោះ [redacted]ចាន់ថា លែងលះពីចុងចម្លើយឈ្មោះ [redacted]នៃឡេង។

២-ឲ្យដើមចោទឈ្មោះ [redacted] ចាន់ថា មានសិទ្ធិអំណាចមេបា លើកូនឈ្មោះ [redacted] ច័ន្ទកណិការ ភេទស្រី កើតថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។

៣-ឲ្យចុងចម្លើយឈ្មោះ [redacted] នៃឡេង បង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៦០០.០០០៛(ហុកសិបម៉ឺន) រៀល ឬ បង់ផ្តាច់ចំនួន ៣០០០$ (បីពាន់) ដុល្លារអាមេរិក។

៤-លះបង់ការទាមទារចំណុចឲ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ៨៨០$។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**ខ-ការពន្យល់ត្រួសៗនៃរឿងក្តី:**

នៅឆ្នាំ២០១២ ដើមចោទឈ្មោះ [redacted] ចាន់ថា និងចុងចម្លើយឈ្មោះ [redacted] នៃឡេង បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ក្នុងការរួមរស់នៅជាមួយគ្នាដើមចោទនិងចុងចម្លើយមានកូនចំនួន

០១នាក់គឺឈ្មោះ [redacted] ច័ន្ទកណិការ ភេទស្រី កើតថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។ ក្រោយមកដើមចោទ និងចុងចម្លើយបានរស់នៅមិនចុះសម្រុងនឹងគ្នា ចុងចម្លើយឈ្មោះ [redacted] ឆៃឡេង ក៏បានចុះចោលចុងចម្លើយនិងកូន ដោយមិនបានផ្តល់ប្រាក់សម្រាប់ផ្គត់ផ្គង់ទំនុកបម្រុង គ្រួសារប្រពន្ធ និងកូននោះទេ ហើយថែមទាំងហានស្រីផ្សេងថែមទៀតធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាមួយនឹងចុងចម្លើយ។

**គ-ការអះអាងរបស់ដើមចោទ:**

ដើមចោទឈ្មោះ [redacted] ចាន់ថា បានធ្វើសេចក្តីថ្លែងការថា: នាងខ្ញុំ បានលះបង់ការទាមទារ លះបង់ការទាមទារចំណុចឲ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ៨៨០$ ក្រៅពីនេះនៅតែធ្វើការទាមទារ ដូចក្នុងកម្មវត្ថុបណ្តឹងដដែល។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា:ក្នុងសំណុំរឿងនេះឃើញថា ចុងចម្លើយអវត្តមាននៅគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការ ហើយតុលាការបានធ្វើការ ជូនដំណឹងទៅចុងចម្លើយ ត្រឹមត្រូវតាមនីតិវិធីច្បាប់រួចហើយ តែចុងចម្លើយនៅតែអវត្តមាន តាមច្បាប់មានន័យថាចុងចម្លើយបានទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ហេតុនេះក្នុងនាមរូបខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទស្នើសុំឲ្យតុលាការចេញសាលក្រមតាមតាមការទាមទាររបស់ដើមចោទ។

**ឃ-ការអះអាងរបស់ចុងចម្លើយ:**

ចុងចម្លើយឈ្មោះ [redacted] ឆៃឡេង អវត្តមានដោយគ្មានមូលហេតុ។ តុលាការបានធ្វើការជូនដំណឹងតាមការផ្សាយជាសាធារណៈ អំពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ត្រឹមត្រូវតាមនីតិវិធីច្បាប់រួចហើយ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ឆៃឡេង ពុំបានចូលរួមក្នុងនីតិវិធី ដែលនេះបានកំណត់នោះទេ ដូចនេះតុលាការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយផ្អែកតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**ង-ចំណុចវិវាទ: គ្មាន**

## <u>សំអាងហេតុ</u>

១-ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ យាត ចាន់ថា ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលដាក់ចូលសាលាដំបូងខេត្តសៀមរាប ឃើញថា ត្រឹមត្រូវតាមទម្រង់ច្បាប់ ហើយក៏ជាសមត្ថកិច្ចរបស់សាលាដំបូងខេត្តសៀមរាប ដែលអាចលើកយកមកធ្វើការសម្រេច និងវិនិច្ឆ័យបានស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

២-ចុងចម្លើយឈ្មោះ [redacted] ឆៃឡេង អវត្តមានដោយគ្មាន មូលហេតុ តាមកំណត់ហេតុបិទផ្សាយលិខិតជូនដំណឹងស្តីពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ និងចុះថ្ងៃទី២៦ ខែមិថុនា ឃើញថាចុងចម្លើយឈ្មោះ [redacted] ឆៃឡេង បានទទួលដំណឹងអំពីដីកាកោះត្រឹមត្រូវតាមបញ្ញត្តិច្បាប់ហើយ តែចុងចម្លើយពុំបានចូលខ្លួនតាមកាលបរិច្ឆេទកំណត់នៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់

ផ្ទាល់មាត់នោះទេ។ យោងតាមមាត្រា ២០១ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា តុលាការចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងទៅនឹងរង្គហេតុ។ ដូចនេះតុលាការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយផ្អែកតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៣-តាមកំណត់ហេតុ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ ឃើញថា តុលាការបានបញ្ជូនឲ្យទៅចុងចម្លើយឈ្មោះ [redacted] ឆៃឡេង នូវសេចក្តីថ្លែងការណ៍របស់ដើមចោទនៅការបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់ហេតុត្រឹមត្រូវច្បាប់ហើយ ដូចនេះតុលាការអាចចេញសាលក្រមកំបាំងមុខចុងចម្លើយបានស្របតាមមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៤-ដើមចោទ និងចុងចម្លើយពិតជាបានរួមរស់នៅជាមួយគ្នាតាំងពីឆ្នាំ២០១២ ប្រាកដមែន មានសំបុត្រអាពាហ៍ពិពាហ៍លេខ ០៦ ចុះថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១២ ដូចនេះការទាមទារសុំលែងលះរបស់ដើមចោទមានភាពត្រឹមត្រូវ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

៥-ដើមចោទឈ្មោះ [redacted] ចាន់ថា ទាមទារគ្រប់គ្រងកូនឈ្មោះ [redacted] ច័ន្ទគណិការ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២ ឃើញថាកូននៅតូចមានអាយុទើបតែ០៧ឆ្នាំ ហើយឈ្មោះ [redacted] ចាន់ថា អាចមានពេលវេលាគ្រប់គ្រាន់ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនបាន។ មួយវិញទៀតចុងចម្លើយឈ្មោះ [redacted] ឆៃឡេង បានចុះចោលដើមចោទ និងកូនដោយមិនបានធ្វើការផ្គត់ផ្គង់គ្រួសារនោះទេ ហេតុនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ដោយឲ្យដើមចោទឈ្មោះ [redacted] ចាន់ថា មានអំណាចមេបាលើកូនឈ្មោះ [redacted] ច័ន្ទគណិការ (មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧)។

៦-ដើមចោទឈ្មោះ [redacted] ចាន់ថា បានទាមទារឲ្យចុងចម្លើយឈ្មោះ [redacted] ឆៃឡេង បង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន៦០០.០០០រ (ហុកសិបម៉ឺន) រៀល ឬបង់ផ្តាច់ចំនួន៣.០០០$ (បីពាន់) ដុល្លារអាមេរិក។ ដោយផ្អែកតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឪពុក ឬ ម្តាយ ដែលមិនមានអំណាចមេបាលើកូន ត្រូវតែធ្វើការបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន។ តែនៅក្នុងសំណុំរឿងនេះ ចុងចម្លើយមិនបានចូលខ្លួននៅគ្រប់នៅតិវិធីហើយតុលាការក៏មិនបានដឹងច្បាស់ អំពីស្ថានភាពជីវភាពរបស់ចុងចម្លើយនោះដែរ ហេតុនេះគួរគប្បីតុលាការសម្រេច ឲ្យចុងចម្លើយបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនទៅតាមលទ្ធភាព។

៧-ចុងចម្លើយឈ្មោះ [redacted] ឆៃឡេង មានសិទ្ធទៅសួរសុខទុក្ខកូនបាន ហើយដើមចោទឈ្មោះ [redacted] ចាន់ថា ដែលមានអំណាចមេបាលើកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីដែលទៅសួរសុខទុក្ខកូន (មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

៧-ដើមចោទឈ្មោះ [redacted] ចាន់ថា នៅក្នុងនីតិត្រៀមសម្រាប់ការទាញហេតុផល និងក្នុងវិធីទាញហេតុផលដោយផ្ទាល់មាត់ បានលះបង់ការទាមទារនូវចំណុច ឲ្យចុងចម្លើយប្រគល់



Scanned with CamScanner

ប្រាក់ចំនួន ៨៨០ $ (ប្រាំបីរយប៉ែតសិប) ដុល្លារអាមេរិក ដូចនេះ តុលាការមិនគួរគប្បីលើកមកធ្វើការពិចារណានិងសម្រេចឡើយ ។

## សេចក្តីសម្រេចបញ្ចប់

១-សុំឲ្យដើមចោទឈ្មោះ [redacted] **ចាន់ថា** លែងលះពីចុងចម្លើយឈ្មោះ [redacted] **នៃឡេង**។

២-ឲ្យដើមចោទឈ្មោះ [redacted] ចាន់ថា ស្ថិតនៅវិធរភាព (ភាពមេម៉ាយ) ចំនួន១២០ ថ្ងៃ (មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា)។

៣-ប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] **ចំន្ទគណិការ** ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២ ឲ្យទៅដើមចោទឈ្មោះ [redacted] **ចាន់ថា** គ្រប់គ្រងចិញ្ចឹមបីបាច់ ថែរក្សាធ្វើការអប់រំ និងមើលការខុសត្រូវ រហូតដល់កូនមានវ័យនីតិភាពចាប់ពីពេលនេះតទៅ។

៤-ភាគីចុងចម្លើយឈ្មោះ [redacted] **នៃឡេង** ដែលពុំមានអំណាចមេបាលើកូនមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដើមចោទឈ្មោះ [redacted] **ចាន់ថា** ដែលមានអំណាចមេបាលើកូនត្រូវបង្កលក្ខណៈងាយស្រួល គ្រប់បែបយ៉ាងដល់ភាគីដែលទៅសួរសុខទុក្ខកូន (មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

៥-ឲ្យចុងចម្លើយឈ្មោះ [redacted] **នៃឡេង** បង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន (អាហារកាតព្វកិច្ចចិញ្ចឹមកូន) ទៅឲ្យដើមចោទឈ្មោះ [redacted] **ចន្ថា** ទៅតាមលទ្ធភាព។

៦-ដើមចោទឈ្មោះ [redacted] **ចាន់ថា** ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅចំពោះមុខដើមចោទឈ្មោះ [redacted] ចាន់ថា និងកំបាំងមុខចុងចម្លើយឈ្មោះ [redacted] នៃលេង។

ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំនត់ច្បាប់។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សៀមរាប,ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner